អន្តរប្រិយ៍

សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ព្រះសម្ពុទ្ធហាមកុំឲ្យមនុស្សលោភ
## តើមានហេតុផលយ៉ាងណា តើការហាមនេះនាំឲ្យបង្អាក់ដំណើរ
## នៃការលូតលាស់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិឬទេ ?

www.hoksavann.org

ថ្ងៃទី១៣ មិថុនា ២០១២



ព្រះសម្ពុទ្ធហាមកុំឲ្យមនុស្សលោភ ពុំបង្អាក់ដំណើរនៃការលូតលាស់សេដ្ឋកិច្ចគ្រួសារ និងសេដ្ឋកិច្ចជាតិឡើយ ដែលមានហេតុផលដូចតទៅនេះ ៖ ព្រះសម្ពុទ្ធសំដែងថា សេចក្ដីលោភជាអកុសលមូលមួយ ក្នុងចំណោមអកុសលមូលទាំង៣គឺ លោភៈ ទោសៈ និងមោហៈ ដែលជាឫសគល់នៃអកុសល ដែលនាំឲ្យមនុស្សសត្វសាងអំពើបាបកម្មផ្សេងៗ ។ ពាក្យថា «លោភ» តាមជំរៅន័យប្រែថា ការជាប់ចិត្តក្នុងវត្ថុនិងមនុស្សសត្វទូទៅ ។ ការជាប់ចិត្តក្នុងខ្លួនឯង ក៏ហៅថាលោភដែរ ។ ក្នុងឧបក្កិលេស១៦មាននិយាយថា អភិជ្ឈាវិសមលោភ ប្រែថាការរំពៃចង់បានទ្រព្យសម្បត្តិអ្នកដទៃដោយគ្មានព្រំដែន ឬចង់បានហួសប្រមាណ ដែលជំរុញឲ្យប្រព្រឹត្តអំពើអាក្រក់ផ្សេងៗ មានប្រព្រឹត្តការលួចប្លន់ជាដើម ។ បើគេពិចារណារកការពិតតាមផ្លូវវិបស្សនា គេឃើញថា ទ្រព្យសម្បត្តិ មនុស្សសត្វ រួមទាំងខ្លួនឯងផង សុទ្ធតែស្ថិតនៅក្នុងភាពពុំទៀងស្ថិតស្ថេរឡើយ គឺតែងតែវិនាសបាត់បង់ទៅវិញជាធម្មតា គ្មានអំណាចណាមួយអាចឃាត់ឃាំងបានឡើយ ។ បើមានចិត្តលោភខ្លាំង តែងបិទបាំងអនិច្ចំ មិនឃើញការពិតថា របស់ទាំងមានវិញ្ញាណណាទាំងគ្មានវិញ្ញាណណា សុទ្ធតែស្ថិតនៅក្នុងការប្រែប្រួលដូរផ្លាស់ជានិច្ច ។ កាលណាបើបានពិចារណានូវភាពពុំទៀងនៃអ្វីទាំងអស់នេះហើយ អាចបន្ថយនូវចិត្តលោភៈ បើថ្នាក់ព្រះអរហន្តជាព្រះអរិយបុគ្គល លោកលះបង់ដោយដាច់ស្រឡះតែម្ដង ។

ការកករល្អក់ផ្លូវចិត្តដោយការលោភៈ ជាកិលេសសៅហ្មងផ្លូវចិត្ត នាំឲ្យចិត្តក្ដៅក្រហាយអន្ទះអន្ទែងជាភ្លើងឆេះក្នុងចិត្ត ដែលហៅថា លោភគ្គិ ដោយចង់បានទ្រព្យសម្បត្តិអ្នកដទៃមកជាទ្រព្យសម្បត្តិរបស់ខ្លួន នេះបើលោភៈមានកម្លាំងខ្លាំង ។ បើចិត្តលោភខ្លាំង រហូតជំរុញកាយវាចាឲ្យបៀតបៀនអ្នកដទៃដោយអំពើហិង្សា ដែលភាសាផ្លូវអាណាចក្រថា រំលោភសិទ្ធិមនុស្ស នឹងត្រូវទទួលទោសក្នុងបច្ចុប្បន្នជាតិនេះ គឺត្រូវគេចាប់ឲ្យឡើងតុលាការ ធ្វើទោសតាមច្បាប់ ។ លុះស្លាប់ទៅសោយទុក្ខក្នុងនរកថែមទៀត ។ សេចក្ដីទុក្ខមួយទៀតដែលកើតឡើងពីការលោភ បើមិនបានប៉ះពាល់សិទ្ធិអ្នកដទៃទេ គ្រាន់តែលោភជាប់ចិត្តជាកម្មសិទ្ធិរបស់ខ្លួន ដូចជាក្រុមគ្រួសារ ម្ដាយឪពុក បងប្អូន កូនចៅ ទ្រព្យសម្បត្តិរបស់ខ្លួនដែលត្រូវវិនាសបាត់បង់ទៅ ខ្លួនក៏ទោមនស្សតូចចិត្តស្ដាយស្រណោះកើតទុក្ខតាមផ្លូវចិត្ត ។

តាមអត្ថន័យដូចរៀបរាប់មកហើយ បង្ហាញយ៉ាងច្បាស់ថា ការដែលព្រះពុទ្ធបានណែនាំមនុស្សសត្វមិនឲ្យលោភ ដើម្បីសេចក្ដីបរិសុទ្ធ ដើម្បីសេចក្ដីសុខ ជៀសវាងទោសទណ្ឌដែលកើតពីចិត្តលោភខ្លាំង រហូតប្រព្រឹត្តចោរកម្មលួចប្លន់ទ្រព្យសម្បត្តិអ្នកដទៃ ដែលកើតមានសេចក្ដីទុក្ខដល់ខ្លួន ។ ជម្រៅជាងនេះទៀត បើខ្លួនមិនមែនជារបស់ខ្លួន ជាខន្ធ៥ តែងប្រព្រឹត្តទៅជាអនិច្ចំ ទុក្ខំ អនត្តា តើការជាប់ចិត្តរបស់ខាងក្រៅខ្លួនដើម្បីអ្វី តាមពិតសង្ខារធម៌តែងប្រព្រឹត្តទៅតាមច្បាប់ធម្មជាតិ គឺកើតឡើងតាំងនៅ និងរលត់ទៅវិញ ។

ការមិនឲ្យលោភ ផ្ទុយគ្នានឹងការរកស៊ីចិញ្ចឹមជីវិត ។ បានសេចក្ដីថា ការដែលព្រះសម្ពុទ្ធហាមមិនឲ្យលោភ តាមព្រះធម៌ទេសនារបស់ព្រះអង្គ ពុំមែនមានន័យថា ព្រះអង្គហាមមិនឲ្យមនុស្សសត្វរកស៊ីចិញ្ចឹមជីវិតឡើយ ។ បើមិនលោភ គឺមិនជាប់ចិត្តរបស់ខ្លួនក្ដីរបស់អ្នកដទៃក្ដី បើរបស់ទាំងនោះវិនាសទៅ ក៏មិនកើតទុក្ខតាមផ្លូវចិត្តឡើយ ។ បានសេចក្ដីថា របស់ដែលមានសំរាប់ប្រើប្រាស់ សំរាប់បរិភោគ ដើម្បីជីវិតរស់នៅ បើរបស់នោះបាត់បង់ទៅក៏មិនកើតទុក្ខ ព្រោះពិចារណាឃើញថា របស់ទាំងអស់តែងតែវិនាសបាត់បង់ទៅវិញតាមច្បាប់ធម្មជាតិ ។ ក្នុងប្រយោជន៍បច្ចុប្បន្ន៤យ៉ាង ព្រះសម្ពុទ្ធបង្រៀនឲ្យមនុស្សខំប្រឹងប្រែងសិក្សារៀនសូត្រ ឲ្យចេះដឹងផ្លូវលោកផ្លូវធម៌ ត្រូវខំរកស៊ីចិញ្ចឹមជីវិតប្រកបដោយធម៌ របស់ដែលរកបានមក ត្រូវខំថែរក្សាឲ្យគង់វង់ ត្រូវចេះចែកចាយទ្រព្យសម្បត្តិឲ្យល្មមចិញ្ចឹមជីវិតបាន និងសេពគប់មិត្តល្អ ។ សូម្បីព្រះសង្ឃព្រះពុទ្ធសាសនាបួសរួចភ្លាម ព្រះឧបជ្ឈាយ៍បានប្រាប់ករណីកិច្ច៤យ៉ាងដែលត្រូវធ្វើ គឺប្រើសំពត់បង្សុកូល និមន្តបិណ្ឌបាត្រ នៅក្រោមម្លប់ឈើ និងប្រាប់គិលានភេសជ្ជបច្ច័យ នេះមូលបញ្ញត្តិ លុះក្រោយមកទើបបញ្ញត្តិជាថ្មី ហៅថាអនុបញ្ញត្តិ គឺបើមានគេប្រគេនសំពត់ត្រៃចីវរ គេប្រគេនចង្ហាន់ អាចទទួលបាន មិនបាច់ស្វែងរកសំពត់ហើយបង្សុកូលយក មិនបាច់បិណ្ឌបាត្របាន ។ ក្នុងបច្ចវេក្ខណ្ណាណដែលព្រះសង្ឃត្រូវពិចារណាក្នុងបច្ច័យទាំង៤ ដើម្បីកុំឲ្យជាប់ចិត្ត (លោភ) គឺបច្ច័យទាំង៤នេះគ្រាន់តែជាធាតុបរិភោគនិងប្រើប្រាស់ ដើម្បីទ្រទ្រង់រាងកាយឲ្យស្ថិតនៅ ដើម្បីប្រព្រឹត្តព្រហ្មចរិយធម៌ប៉ុណ្ណោះ ។

* *

*